ក្រសួង ឧស្សាហាកម្ម ទេសចរណ៍ និងពាណិជ្ជកម្ម

# ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពសារធាតុគីមី និងជីក្នុងវិស័យកសិកម្ម

## ឧបករណ៍Back flow prevention devices(ទប់កុំឱ្យចរន្តទឹករត់បញ្ច្រាសមកវិញ)

មានការណែនាំឱ្យដឹងថា ការប្រើឧបករណ៍ back flow prevention devices (ទប់កុំឱ្យទឹករត់បញ្ច្រាសមកវិញ) គឺជាលក្ខខណ្ឌចាំបាច់ សម្រាប់អ្នកដាំដំណាំទាំងឡាយ ដែលប្រើប្រាស់វិធីស្រោចស្រពសារធាតុគីមី និងជីក្នុងវិស័យកសិកម្ម នៅលើដីរបស់ខ្លួន។

ការរៀបចំឱ្យមានប្រព័ន្ធទាំងនោះ គឺធ្វើឡើងដើម្បីការពារបរិស្ថាន និងសុខភាពមនុស្ស ដោយការការពារប្រព័ន្ធទឹក រ និងប្រភពធនធានទឹកនៅក្រោមដី កុំឱ្យមានការឆ្លងប៉ះពាល់សារធាតុគីមី។

លក្ខខណ្ឌជាក់លាក់មួយចំនួនដែលតម្រូវនៅក្នុងដែនដីភាគខាងជើងប្រទេសអូស្ត្រាលីគឺ៖

- ការដំឡើងឧបករណ៍ reduced pressure zone device ឬឧបករណ៍ registered air gap គឺជាតម្រូវការចាំបាច់
- មិនត្រូវមានចំណុចឬផ្នែកណាមួយនៃការបញ្ចេញ ឬបាញ់បញ្ចូល រវាងប្រភពទឹកក្រោមដី និងឧបករណ៍ back flow prevention devices ឡើយ។
- ចំណុចល្បាយគឺដាច់ដោយឡែកពីក្បាលម៉ាស៊ីនបូមទឹកនិងចំណុចបញ្ចូល/ដាក់ចូល ហើយមានការទប់ពាំងសមស្រប ដើម្បីការពារកុំឲ្យមានការបញ្ចេញឬជ្រាបទៅក្នុងលម្ហបរិស្ថាន។ ឧទាហរណ៍ ការប្រើទំនប់/ខឿន ឬការចាក់បេតុងស៊ីម៉ង់ទប់ការពារកុំឱ្យមានការជ្រាបសាយភាយ(សារធាតុគីមី)មកខាងក្រៅ។

បច្ចុប្បន្ននេះ ការត្រួតពិនិត្យកំពុងអនុវត្តឡើងនៅតំបន់ជនបទ ដើម្បីជួយដល់ម្ចាស់ដី(ម្ចាស់ចំការ) ក្នុងការកំណត់ និងកែតម្រូវពីការខ្វះខាតនានា។

ចំពោះព័ត៌មានបន្ថែម លោកអ្នកអាចសុំពីក្រសួងឧស្សាហាកម្ម ទេសចរណ៍ និងពាណិជ្ជកម្ម។

សូមទាក់ទងអ្នកសម្របសម្រួលខាងផ្នែកសារធាតុគីមី តាមរយៈទូរសព្ទលេខ 08 8999 2199 ឬអ៊ីម៉ែលទៅ **Chemicals.DITT@nt.gov.au**



*ការដំឡើងត្រឹមត្រូវ*



*ការដំឡើងមិនត្រឹមត្រូវ*